Habitat for Humanity® Cambodia

ប្រវត្តិការណ៍

អង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា

១ កក្កដា ២០០៩ - ៣០ មិថុនា ២០១០

១ បេសកកម្ម

អង្គការលំនៅដ្ឋានមនុស្សជាតិធ្វើការក្នុងភាពជាដៃគូជាមួយមនុស្សគ្រប់ទិសទី គ្រប់អាជីព និងគ្រប់ស្រទាប់វណ្ណៈ ដើម្បីអភិវឌ្ឍសហគមន៍ជួយដល់អ្នកខ្វះខាត និងមានតម្រូវការ ដោយសាងសង់ និងជួសជុលគេហដ្ឋានឲ្យប្រសើរឡើងវិញ ដើម្បីឲ្យមានលំនៅដ្ឋានសមរម្យនៅក្នុងសហគមន៍កំពុងលូតលាស់ ដែលប្រជាជនអាចទទួលបាននូវសេចក្តីស្រលាញ់របស់ព្រះ និងអាចរស់នៅ និងធំធាត់នៅក្នុងគោលបំណងទាំងអស់របស់ព្រះ។

២ ទស្សនវិស័យ

ពិភពលោកមួយ ដែលមនុស្ស គ្រប់រូបមានទីន្លែងសមរម្យ សម្រាប់រស់នៅ។



៣ គោលបំណង

គោលបំណងសំខាន់បំផុតរបស់អង្គការ លំនៅដ្ឋានមនុស្សជាតិ គឺដើម្បីលុបបំបាត់នូវភាពខ្វះខាត និងភាពគ្មានលំនៅដ្ឋាននៅលើផែនដី ដោយសាងសង់លំនៅដ្ឋានជាមូលដ្ឋាន និងឲ្យបានគ្រាប់គ្រាន់។

គ្រប់ពាក្យសំដី និងសកម្មភាពរបស់យើង គឺធ្វើឡើងដើម្បីសម្រេចបាននូវគោលបំណងសំខាន់បំផុតក្នុងការធ្វើឲ្យមនុស្សទាំងអស់ចងចាំនូវបញ្ហាទីជម្រកតាមវិធីដែលមានប្រសិទ្ធភាពមួយថា ភាពខ្វះខាត និងភាពគ្មានលំនៅដ្ឋាន គឺជាកត្តាមួយដែលមិនអាចទទួលយកបានទាំងផ្នែកសង្គម ផ្នែកនយោបាយ និងផ្នែកសាសនានៅក្នុងសង្គមជាតិ និងពិភពលោករបស់យើង។

សាររបស់នាយិកា

នៅក្នុងឆ្នាំនៃបញ្ហាគ្រោះមហន្តរាយធ្ងន់ធ្ងរ និងការស្រុតចុះផ្នែកសេដ្ឋកិច្ចអង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជាបានបង្កើតឲ្យមានព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយក្នុងការជួយដល់គ្រួសារប្រជាជនកម្ពុជាជាង ១០០០ គ្រួសារ។ យើងសប្បាយរីករាយណាស់ដែលឆ្នាំនេះអង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា បានជួយគ្រួសារកម្ពុជារហូតដល់ទៅស្ទើរតែបីដងលើសឆ្នាំមុន។ ទោះបីជាកំពុងតែប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរក៏ដោយក៏អង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជានៅតែបានជួយសាងសង់ និងជួសជុលលំនៅដ្ឋានបានរហូតដល់ ១៤៥ ខ្នង ជួយប្រជាជនចំនួន ៨៣៨ គ្រួសារ ឲ្យទទួលបានទឹកស្អាតប្រើប្រាស់ និងមានអនាម័យប្រសើរជាងមុន និងបណ្តុះបណ្តាលសមាជិកក្នុងសហគមន៍ជាង ១០០០នាក់ឲ្យយល់ដឹងពីសកម្មភាពផ្សេងៗ ក្នុងការប្រកបរបរប្រចាំថ្ងៃ។ ភាគច្រើននៃការងារទាំងនេះធ្វើឡើងដោយមានជំនួយពីអ្នកស្ម័គ្រចិត្តអន្តរជាតិចំនួន ៥០០ នាក់ ដែលបានចូលរួមក្នុងកម្មវិធីដ៏មានប្រជាប្រិយភាពមួយឈ្មោះកម្មវិធី គ្លូបិលវីលេជ (Global Village) របស់អង្គការលំនៅដ្ឋានដើម្បីធ្វើការនៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំសូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយសប្បុរសធម៌ទាំងអស់ ក្នុងការផ្តល់នូវធនធានរបស់ពួកគេដើម្បីធ្វើឲ្យការរស់នៅរបស់អ្នកដទៃកាន់តែប្រសើរឡើង។ ក្តីសុបិន្តរួមគ្នារបស់ពួកយើងនឹងមិនអាចក្លាយជាការពិតទេ ប្រសិនបើគ្មានការចូលរួមពីពួកគាត់។

ក្នុងឆ្នាំ ២០០៩យើងមានមោទនភាពណាស់ដែលអង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជាបានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកម្មវិធីសម្រាប់អ្នកស្ម័គ្រចិត្តជាតិ និងអន្តរជាតិចំនួន ២៣១ នាក់ ក្នុងកំឡុងពេលប្រារព្ធធ្វើគម្រោងការងារដើមី និង រ៉ូសាលីន ខាធើ (Jimmy and Rosalynn Carter Work Project) ការសាងសង់តំបន់មេគង្ក។ អង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា និងដៃគូរបស់ខ្លួន មានកិត្តិយសដោយទទួលបានការអញ្ជើញចូលរួមរបស់លោក ជីមី ខាធើ (Jimmy Carter) ដែលជាអតីតប្រធានាធិបតីសហរដ្ឋអាមេរិក និងភរិយារបស់លោក គឺអ្នកស្រី

រ៉ូសាលីន (Rosalynn) ឯកឧត្តមសុខអាន ឧបនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា អ្នកដឹកនាំអភិវឌ្ឍ និងបណ្តារវាស្សជនជាតិជាច្រើននាក់ទៀតដែលបានចូលរួមក្នុងការសម្ពោធលំនៅដ្ឋានថ្មីចំនួន ២១ខ្នង ដែលសាងសង់ឡើងក្នុងរយៈពេលតែមួយសប្តាហ៍។ គម្រោងនេះ បានទទួលជោគជ័យយ៉ាងខ្លាំង ហើយអង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា គ្រោងនឹងប្រារព្ធពិធីខួបគម្រប់មួយឆ្នាំ នៅក្នុងខែវិច្ឆិការ ឆ្នាំ ២០១១ ខាងមុខនេះ។ អង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា ក៏បានចាប់ផ្តើមគម្រោងមួយដែលមានឈ្មោះថា ការសាងសង់កម្ពុជា (CambodiaBUILDS) ក្នុងកំឡុងពេលគម្រោងការងារខាធើ (Carter Work Project)។ គម្រោងការសាងសង់កម្ពុជា គឺជាគម្រោងយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ ដើម្បីផ្តល់នូវលំនៅដ្ឋានកាន់តែមានភាពប្រសើរឡើងដល់គ្រួសារកម្ពុជាដែលមានប្រាក់ចំណូលទាបចំនួន១០,០០០ គ្រួសារ និងជម្រុញលើកទឹកចិត្ត ការចូលរួមរបស់បុគ្គល ក្រុមផ្សេងៗ អង្គការ និងរដ្ឋាភិបាល។

នៅក្នុងខែ ឧសភា ឆ្នាំ ២០១០ អង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា បានចាប់ផ្តើមគម្រោងសាកល្បងមួយដែលមានឈ្មោះថា "កម្មវិធីដោះស្រាយលំនៅដ្ឋានធ្វើឲ្យប្រសើរឡើងដល់អ្នកជម្ងឺអេដស៍ និងកុមារកំព្រាងាយរងគ្រោះ" ដែលនឹងផ្តល់នូវលំនៅដ្ឋានប្រកបដោយសន្តិសុខដល់កុមារកំព្រា និងកុមារងាយរងគ្រោះ (OVC) និងអ្នករងផលប៉ះពាល់ដោយសារមេរោគអេដស៍/ជម្ងឺអេដស៍ ចំនួន ៣២០ នាក់ ដោយធ្វើការជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិចំនួន ៤ ដែលបច្ចុប្បន្នកំពុងតែដំណើរការកម្មវិធីជួយដល់កុមារកំព្រា និងកុមារងាយរងគ្រោះប្រកបដោយជោគជ័យនៅក្នុងប្រទេសកម្ពុជា។

ក្នុងកំឡុងឆ្នាំ ២០១០ យើងបានវាយតម្លៃគម្រោងអភិវឌ្ឍលំនៅដ្ឋាន និងសហគមន៍របស់យើងដើម្បីស្វែងរកមេរៀនជាបទពិសោធន៍ និងការអនុវត្តន៍ល្អៗ សម្រាប់ពង្រឹងដល់សហគមន៍ និងលើកឡើងនូវតម្រូវការរបស់សហគមន៍យើង។ យើងក៏បានពិនិត្យមើលឡើងវិញនូវផែនការយុទ្ធសាស្ត្ររបស់យើងផងដែរ។ អនុសាសន៍លេចធ្លោដ៏ល្អពីរ ជាវិស័យដែលអង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជាអាចដើរតួនាទីយ៉ាងសំខាន់ នោះគឺការកាត់បន្ថយគ្រោះមហន្តរាយ និងការផ្តល់ហិរញ្ញប្បទានខ្នាតតូចសម្រាប់ទឹកស្អាត និងអនាម័យ។ អង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា គ្រោងនឹងបង្កើននូវការទទួលបានហិរញ្ញវត្ថុ និងការផ្តល់យោបល់ផ្នែកបច្ចេកទេសសម្រាប់ទឹកស្អាត និងអនាម័យ ក៏ដូចជា ការកាត់បន្ថយមហន្តរាយដល់ប្រជាពលរដ្ឋដែលរស់នៅតំបន់ជនបទ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ភាពជាដៃគូជាមួយធនាគារពិភពលោក អាជ្ញាធរក្នុងខេត្តបាត់ដំបង និងសហគមន៍អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលជួយឲ្យយើងកាន់តែដើរខិតទៅមុខ ទាក់ទងលើបញ្ហាកម្មសិទ្ធិដីធ្លីសម្រាប់គ្រួសារដែលរស់នៅក្នុងតំបន់សួនច្បារបំរុង (Reserved Garden) ក្នុងខេត្តបាត់ដំបង។

ក្នុងនាមជាអង្គការមួយក្នុងចំណោមអង្គការតិចតួចដែលធ្វើការលើបញ្ហាលំនៅដ្ឋាននៅក្នុងប្រទេសកម្ពុជា អង្គការលំនៅដ្ឋាន កំពុងតែធ្វើការ និងបង្កើនភាពជាដៃគូជាមួយស្ថាប័ន និងអង្គការជាច្រើនទាំងក្នុងស្រុក និងអន្តរជាតិ ដើម្បីផ្តល់ឱកាសដល់បុគ្គល គ្រួសារ ម្ចាស់ជំនួយដែលធ្វើការរួមគ្នា អង្គការមិនរកប្រាក់កម្រៃ អ្នកដឹកនាំថ្នាក់សហគមន៍ អ្នកអប់រំ ក៏ដូចជា អ្នកដែលកំពុងរស់នៅក្នុងផ្ទះដែលសង់ឡើងមិនគ្រប់តាមបទដ្ឋាន ដើម្បីរួមចំណែកក្នុងគម្រោងដីធ្លីលំនៅដ្ឋាន និងការរស់នៅប្រកបដោយនិរន្តរភាពរបស់យើង។ យើងនឹងចែករំលែកនូវព័ត៌មានអំពីភាពរីកចម្រើនរបស់យើង នៅក្នុងកិច្ចខិតខំប្រឹងប្រែងដ៏គួរឲ្យកោតបរិយាយនេះក្នុង ឆ្នាំ ២០១១។

ជាមួយនឹងការគាំទ្ររបស់អ្នក យើងនឹងនៅតែបន្តធ្វើជាដៃគូសំខាន់ក្នុងការបំពេញនូវតម្រូវការលំនៅដ្ឋានរបស់គ្រួសារប្រជាជនកម្ពុជា។ ការប្តេជ្ញាចិត្តរបស់អ្នកស្ម័គ្រចិត្ត និងបុគ្គលិករបស់យើងចំពោះបំណងប្រាថ្នារបស់ដៃគូក្នុងស្រុករបស់យើង និងចក្ខុវិស័យរបស់ម្ចាស់ជំនួយដើម្បីធ្វើឲ្យសហគមន៍មានភាពប្រសើរឡើង គឺជាផ្នែកដ៏សំខាន់នៃអ្វីៗដែលយើងបានធ្វើ។ យើងនឹងព្យាយាមជួយដល់ដៃគូរបស់យើងឈានទៅសម្រេចគោលដៅអភិវឌ្ឍរបស់ពួកគេដើម្បីផលប្រយោជន៍ដ៏ធំធេងរបស់ប្រជាជនកម្ពុជានៅតាមសហគមន៍។ ខណៈដែលយើងបន្តដំណើរទៅមុខ គោលបំណងរបស់អង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា គឺបន្តធ្វើជាដៃគូរបស់អ្នកទាំងអស់គ្នាក្នុងការផ្តល់នូវលំនៅដ្ឋានដែលជាតម្រូវការចាំបាច់បំផុត។

យើងខ្ញុំសង្ឃឹមថា លោកអ្នកនឹងរីករាយជាមួយការចែករំលែកនូវស្នាដៃសំខាន់ៗ របស់ពួកយើង។

Jimmy

ជីណាដេត ប៊ីឡូឌ្យូធី
នាយិកា

២,៨១៦

បុរស ស្ត្រី និងកុមារទទួលបាន
វគ្គបណ្តុះបណ្តាលស្តីអំពីសុខភាព
បឋម និងអនាម័យ

១,៨៦០

គ្រួសារត្រូវបានជួយរហូតមក
ដល់ពេលបច្ចុប្បន្ន

១,០៥២

គ្រួសារត្រូវបានជួយនៅក្នុង
ឆ្នាំការងារទី១០

៨៣៨

គ្រួសារមានទឹកស្អាត និងបង្គន់
អនាម័យសម្រាប់ប្រើប្រាស់

១៤៥

គ្រួសាររស់នៅក្នុងលំនៅដ្ឋានសាមញ្ញ
តំលៃល្មម និងសមរម្យ

ស្ថានភាពលំនៅដ្ឋាន នៅក្នុងប្រទេសកម្ពុជា

៨៨%
នៃប្រជាជនស្លាប់ដោយសារជម្ងឺ រាគរូសដោយការប្រើប្រាស់ទឹកគ្មានសុវត្ថិភាព កង្វះអនាម័យត្រឹមត្រូវ និងគ្មានឧបករណ៍មានអនាម័យប្រើប្រាស់ (របាយការណ៍របស់អង្គការសុខភាពពិភពលោក)

៨៨%
នៃគ្រួសារ នៅក្នុងស្រុកអង្គរជុំ ខេត្តសៀមរៀប គ្មានបង្គន់អនាម័យ (នាយកដ្ឋានស្ថិតិ នៃក្រសួងផែនការឆ្នាំ ២០០៩)

៦៣.៦%
នៃសហគមន៍នៅក្នុងស្រុកអង្គរជុំ ប្រើប្រាស់ទឹកគ្មានសុវត្ថិភាព (នាយកដ្ឋានស្ថិតិ នៃក្រសួងផែនការ ឆ្នាំ ២០០៩)

៣៥%
នៃប្រជាជនកម្ពុជារស់នៅក្រោមបន្ទាត់ក្រីក្រថ្នាក់ជាតិដែលស្មើនឹង ០.៤៥ ដុល្លារអាមេរិក ក្នុងមួយថ្ងៃ- (របាយការណ៍អភិវឌ្ឍមនុស្សរបស់អង្គការ UNDP ឆ្នាំ២០០៩)

១នាក់
ក្នុងចំណោមប្រជាជនកម្ពុជា ៤ នាក់ គឺជាប្រជាជនក្រីក្រ

១នាក់
ក្នុងចំណោមមនុស្ស ៣នាក់ រស់នៅជនបទបានទទួលទឹកពិសារដែលមានសុវត្ថិភាព (គោលដៅអភិវឌ្ឍ សហសវត្សកម្ពុជា)

៤១០
កន្លែង នៅទីក្រុងភ្នំពេញជាតំបន់សំណង់អនាធិបតេយ្យ (សមាគមធាងត្នោត ឆ្នាំ ២០០៩)

៤០,៥៤៨
ជាប្រជាជនក្រីក្រមានទីលំនៅក្នុងតំបន់សំណង់អនាធិបតេយ្យ (សមាគមធាងត្នោត ឆ្នាំ ២០០៩)

លំនៅដ្ឋាន និងទីជំរក

ចាប់ពីឆ្នាំ ២០០៣:
៤៧៧ គ្រួសារ **បានរស់**
នៅក្នុងលំនៅដ្ឋានសមរម្យ
និងមានសុវត្ថិភាព

“ លំនៅដ្ឋានថ្មីនេះ ធ្វើឲ្យខ្ញុំ និងគ្រួសាររបស់ខ្ញុំរស់នៅ ប្រកបដោយភាពសុខដុមរមនា និងចម្រុងចម្រើន ”

ទាយ ហេវី គ្រួសារដ៏គួររបស់អង្គការលំនៅដ្ឋាន នៅក្នុងខេត្តសៀមរាប

១,១៧៧
ប្រជាជនរស់នៅក្នុងផ្ទះដែលមានសុវត្ថិភាព និងមានអគ្គីសនីប្រើប្រាស់គ្រប់គ្រាន់

១៧៤
ជាងសំណង់ក្នុងស្រុកទទួលបានវគ្គបណ្តុះបណ្តាលផ្នែកសាងសង់

១០៩
ផ្ទះថ្មីត្រូវបានសាងសង់

៦៩
ផ្ទះទទួលបានការតភ្ជាប់ប្រព័ន្ធអគ្គីសនី

៣៦
ផ្ទះត្រូវបានជួសជុល

៣១
ភូមិនៅក្នុងខេត្តសៀមរាប

៨
តំបន់ជាយក្រុងនៅក្រុងភ្នំពេញ

២
ភូមិនៅក្នុងខេត្តកណ្តាល

ទឹកស្អាត និងអនាម័យ

អង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា កំពុងផ្តល់នូវប្រាក់កម្ចីខ្នាតតូចដែលមាននិរន្តភាព ដែលផ្តោតទៅលើតម្រូវការទឹក និងអនាម័យ សម្រាប់គ្រួសារប្រជាជនកម្ពុជា រួមមាន អណ្តូងទឹក បង្គន់អនាម័យ ធុងចម្រោះទឹក និងពងទឹក។

កាន កែវ

កាន កែវ អាយុ ១៦ឆ្នាំ ជាសិស្សនៅសាលាបឋមសិក្សា ប្រាសាទ ត្រាវ ក្នុងខេត្តសៀមរាប ។ កាលពីមួយឆ្នាំមុន ដែលអង្គការលំនៅដ្ឋាន បានជួយសង់បង្គន់ និងភ្ជាប់ប្រភពទឹកនៅផ្ទះរបស់គាត់ គាត់មិនដែលបានប្រើប្រាស់បង្គន់អនាម័យទេ ។ ឥឡូវនេះ គាត់តែងតែប្រើប្រាស់បង្គន់អនាម័យ ជាជាងការដើរទៅបន្ទោរបង់នៅក្នុងវាលស្រែដូចពីមុន ។ នៅពេលដែល កាន កែវ បានដឹងពីសារៈសំខាន់នៃការប្រើប្រាស់បង្គន់ ការលាងសម្អាតដៃ និងប្រើប្រាស់ទឹកស្អាតដើម្បី សុខភាពគាត់ និងក្រុមគ្រួសាររបស់គាត់ អាចផ្ទាស់ប្តូរទទួលយកការអនុវត្តន៍ដើម្បីសុខភាពល្អទាំងនេះ ។ ការអនុវត្តន៍ដើម្បីសុខភាពល្អ ធ្វើឲ្យគ្រួសារមានសុខភាពល្អ ។ គ្រួសារដែលអាចរកប្រាក់ចំណូលបានច្រើនកូន។ អាចចូលសាលាទៀតទាត់ និងធ្វើឲ្យអនាគតកាន់តែភ្លឺស្វាង ។

២,១៣៤ នាក់
ប្រជាជនមានទឹកស្អាត និងបង្គន់អនាម័យប្រើប្រាស់

២៧១
តភ្ជាប់ប្រព័ន្ធទឹកស្អាត ពងទឹក និងធុងចម្រោះទឹក ត្រូវបានចែកជូន

១៦០
សមាជិកសហគមន៍ទទួលវគ្គបណ្តុះបណ្តាលលើបញ្ហាទឹកស្អាត និងអនាម័យ

៥៦
អណ្តូងទឹកត្រូវបានធ្វើពិសោធន៍

៤២
អណ្តូងទឹកចំហរត្រូវបានជីក

៣២
បង្គន់អនាម័យតាមផ្ទះត្រូវបានសាងសង់

២៩
អណ្តូងស្នប់ត្រូវបានបំពាក់

១២
អាងស្តុកទឹកភ្ជៀងត្រូវបានសាងសង់

២
បង្គន់អនាម័យសហគមន៍ត្រូវបានសាងសង់

សុវត្ថិភាពដីធ្លី សម្រាប់លំនៅដ្ឋាន

ដោយមានជំនួយពីធនាគារពិភពលោក និងមូលនិធិអភិវឌ្ឍសង្គមជប៉ុន និងក្នុងភាពជាដៃគូជាមួយអាជ្ញាធរស្រុកបាត់ដំបង និងអង្គការមិនមែនរដ្ឋាភិបាល អង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា មានបំណងនឹងបង្កើនគុណភាពលំនៅដ្ឋានដែលមានស្រាប់ចំនួន ៣០០ ខ្នង និងផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនចំនួន ១០០ គ្រួសារ ពីសហគមន៍ គ្មានរបៀបរៀបរយ ទៅកាន់តំបន់សួនច្បារបំរុងនៅក្នុងខេត្តបាត់ដំបង ។

ធ្នូ ២០០៧

មានដីសម្បទានសង្គមកិច្ចនៅតំបន់ជាយក្រុងចំនួន ៦៧.៦០០ ម៉ែត្រការ៉េ (ក្រុងបាត់ដំបង)

សីហា ២០០៩

មានការប្រកាសបញ្ចប់គម្រោង - Cut Off Date

ធ្នូ ២០០៩

អភិបាលខេត្តបាត់ដំបងបានប្រកាសការអនុម័តដីសាធារណៈជាដីកម្មសិទ្ធិឯកជន

អ្នកស្ម័គ្រចិត្ត

"ខ្ញុំមានអារម្មណ៍រំភើបខ្លាំងណាស់ ដែលខ្ញុំមានឱកាសចូលរួមជួយសាងសង់ផ្ទះសម្រាប់ប្រជាជនៗ ខ្ញុំស្រ្ចប់ស្រ្ចាងប្រជាជនកម្ពុជា ។ ខ្ញុំគិតថា យើងមានរឿងជាច្រើនត្រូវរៀនសូត្រពីពួកគាត់ ។"

ខូលីន ណេលសុន អ្នកស្ម័គ្រចិត្តមកពីចក្រភពអង់គ្លេស

៦៨៨
អ្នកស្ម័គ្រចិត្តចូលរួមសរុប

៥០០
អ្នកស្ម័គ្រចិត្តអន្តរជាតិ

១៨៨
អ្នកស្ម័គ្រចិត្តជាតិ

២២
ក្រុមគ្ជូ៊ីលវ៉ីលេជ



$១២១,៥៤៤.១២
ប្រាក់បរិច្ចាគ

៤៥
ផ្ទះត្រូវបានសាងសង់

២២
អណ្តូងត្រូវបានជីក

សាលា១
ខ្នងត្រូវបានលាបពណ៌

Habitat for Humanity® Cambodia

ដំណោះស្រាយ ពណ៌បៃតង

* ធ្វើការស្ទាបស្ទង់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ទៅលើគំរូលង់ផ្ទះបែបប្រពៃណី
* ស្នើផ្តល់ជូននូវឧបករណ៍ពង្រឹងស្ថានភាពផ្ទះ ដើម្បីទប់ទល់ទៅនឹងគ្រោះមហន្តរាយ



៣២,៨០០ ដុំឥដ្ឋ
ដីផលិតដោយដៃត្រូវបានផលិត

៩៨
ជាងសំណង់ក្នុងស្រុកទទួលបានវគ្គបណ្តុះបណ្តាលផ្នែកពង្រឹងស្ថានភាពផ្ទះទប់ទល់នឹងគ្រោះមហន្តរាយ

៣១
ផ្ទះសាងសង់ឡើងដោយប្រើប្រាស់ឥដ្ឋផលិតដោយដៃ

២៥
ជាងសំណង់ក្នុងស្រុកទទួលបានវគ្គបណ្តុះបណ្តាលពីបច្ចេកទេសផលិតប្រភេទឥដ្ឋផ្សេងៗ

២១
ផ្ទាំងចាមពលពន្លឺព្រះអាទិត្យត្រូវបានបំពាក់តាមផ្ទះ

១
អណ្តូងទឹកដំនើការដោយផ្ទាំងចាមពលពន្លឺព្រះអាទិត្យ

ការកសាងសហគមន៍

អង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា កំពុងផ្តល់នូវប្រាក់កម្ចីខ្នាតតូចដែលមានការប្រាក់ទាប សម្រាប់ឱកាសប្រកបរបរចិញ្ចឹមជីវិត និងបង្កើនប្រាក់ចំណូលប្រចាំថ្ងៃដល់គ្រួសារប្រជាជនកម្ពុជា។

លោក រស់ សារឿន

គ្រួសារដៃគូររបស់អង្គការលំនៅដ្ឋាន

"នេះគឺជាវគ្គបណ្តុះបណ្តាល ដ៏មានសារៈប្រយោជន៍មួយ។ វាជួយឲ្យខ្ញុំយល់ដឹងកាន់តែច្រើនអំពីជំនាញក្នុងការសាងសង់ និងអាចបង្ហាត់បង្រៀនជំនាញនេះដល់អ្នកដទៃថែមទៀតផង។ ក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាលនេះខ្ញុំ និងប្រពន្ធរបស់ខ្ញុំមានអារម្មណ៍សប្បាយរីករាយណាស់ ព្រោះយើងបានរៀនជំនាញថ្មីមួយទៀត មានការងារថ្មីទៀត និងអាចរកប្រាក់ចំណូលសម្រាប់សន្សំទុកបានច្រើន។"

អ្នកស្រី ច័ន្ទ្ធ រី

អ្នកតំណាងភូមិ សែន សុខ ក្រុងភ្នំពេញ

"ភាពជាអ្នកដឹកនាំ ជួយដល់សហគមន៍ឲ្យយល់ពីអ្វីដែលកំពុងកើតមានឡើង និងជួយបណ្តុះសមត្ថភាព។"



២,៨១៦
បុរស ស្ត្រី និងកុមារទទួលបានវគ្គបណ្តុះបណ្តាលស្តីអំពីសុខភាពបឋម និងអនាម័យ

៥០៥
បុរស និងស្ត្រី ទទួលបានវគ្គបណ្តុះបណ្តាលទៅលើជំនាញហិរញ្ញវត្ថុ ជំនាញគ្រប់គ្រងអាជីវកម្ម និងការប្រកបរបររស់នៅ

៤៩៤
បុរស និងស្ត្រីបានទទួលគ្រាប់ពូជបន្លែ

៨៧
បង្កើតក្រុមសន្សំប្រាក់

២០
សហគមន៍ភូមិត្រូវបានបង្កើត

១០
បុរស និងស្ត្រីទទួលវគ្គបណ្តុះបណ្តាលជំនាញភាពជាអ្នកដឹកនាំ

មន្ត្រីរដ្ឋាភិបាល

ឯកឧត្តម សុខ អាន - *ឧបនាយករដ្ឋមន្ត្រី និងលោកជំទាវ*
ឯកឧត្តម ម៉ាន់ ឈឿន - *អតីតអភិបាលក្រុងរាជធានីភ្នំពេញ*
ឯកឧត្តម ឈុន ស៊ីរុន - *អភិបាលខេត្តកណ្តាល*
លោក ពុង សាមី - *អភិបាលស្រុកពញ្ញាឮ*

ភ្ញៀវកិត្តិយស

ជ័យលាភីរង្វាន់ណូបែលសន្តិភាព និងជាអតីតប្រធានាធិបតីសហរដ្ឋអាមេរិក លោក ជីមី ខាធើ
និងភរិយា រ៉ូសាលីន ខាធើ, ឯកអគ្គរដ្ឋទូតអាមេរិកលោកស្រី ខារ៉ូល រ៉ដលី

ម្ចាស់ជំនួយក្នុងការសាងសង់លំនៅដ្ឋាន

អង្គការ អាយស៊ីស៊ីអេ, កូអ៊ីកា, អង្គការលំនៅដ្ឋានមនុស្សជាតិញូវហ្សេឡេន,
អង្គការលំនៅដ្ឋានមនុស្សជាតិចិន, សេវាកម្មហិរញ្ញវត្ថុ ជាលើរ និង អង្គការលំនៅដ្ឋានមិត្តសំឡាញ់

អ្នកឧបត្ថម្ភ

ប៉ូល និងអាយលីន មុន, ធនាគា ANZ រ៉ូយ៉ាល់, ខ្មែរសូឡា, Campaint,
Great Alliance, សារព័ត៌មានភ្នំពេញប៉ុស្ត៍

"បន្ទាប់ពីផ្ទាស់ទីលំនៅទៅស្រុកឧត្តុង្គ និងទទួលបានផ្ទះមានសុវត្ថិភាពរួចមក ខ្ញុំអាចមើលឃើញថា ជីវិតរបស់យើងមានភាពល្អប្រសើរជាងមុន ជាពិសេសគឺសុខភាពរបស់យើង ។ យើងកម្រនឹងមានជម្ងឺ ពីព្រោះទីនេះមានខ្យល់កាអាកាសច្រើន ។ ជាង់នេះទៅទៀត យើងទទួលបានទឹកស្អាត និងអគ្គិសនីប្រើប្រាស់ដោយឥតគិតថ្លៃ (ទទួលបានពីឧបករណ៍ស្រូបពន្លឺព្រះអាទិត្យ) ហើយយើងអាចកាត់បន្ថយចំណាយ និងបង្កើនទូវការសន្សំរបស់យើង "

សំដីរបស់គ្រួសារដ៏គុរអង្គការលំនៅដ្ឋាន នៅពេលដែលបានសួរថា តើជីវិតរបស់គាត់មានការផ្លាស់ប្តូរដូចម្តេចបន្ទាប់ពីបានក្លាយជាម្ចាស់ផ្ទះលើកទីមួយ

Habitat for Humanity® Cambodia

Jimmy & Rosalynn CARTER WORK PROJECT
THE MEKONG BUILD 2009

ឌួបប្រចាំឆ្នាំលើកទី ២៦ របស់អង្គការលំនៅដ្ឋានមនុស្សជាតិ
គម្រោងការងារ ជីមី និងរ៉ូសាលីន ខាធើ
ការសាងសង់តំបន់មេគង្គ

៥ ប្រទេស: កម្ពុជា ថៃ វៀតណាម ចិន និងឡាវ

ថ្ងៃទី ១៦ - ២០ ខែវិច្ឆិកា ឆ្នាំ ២០០៩



" នេះគឺជាការធ្វើបដិសណ្ឋារកិច្ចដ៏អស្ចារ្យដែលយើងមិនធ្លាប់បានទទួលនៅលើពិភពលោកនេះ ។ អស់រយៈពេល ២៦ ឆ្នាំ ហើយដែលខ្ញុំ និងភរិយាបានធ្វើដំណើរទៅកាន់កន្លែងសាងសង់លំនៅដ្ឋានរបស់អង្គការ Habitat ។ យើងមិនដែលបានទទួលនូវស្វាគមន៍ដែលរំភើបដូចនេះទេ ហើយយើងក៏មិនដែលឃើញកន្លែងណាដែលស្រស់ស្អាតជាងកន្លែងនេះដែរ ។ "

លោក ជីមី ខាធើ ជាអតីតប្រធានាធិបតីសហរដ្ឋអាមេរិក
បានមានប្រសាសន៍ក្នុងដំណើរទស្សនកិច្ចទៅកាន់
សហគមន៍ជីវិតថ្មី នៅឧត្តុង្គ ខេត្តកណ្តាល

១០៥
ប្រជាជនរស់នៅក្នុងលំនៅដ្ឋានសមរម្យ និងដ៏ត្លីមានសុវត្ថិភាព

១0,000លីត្រ
ចំនុះអាងស្តុកទឹកចំនួនមួយ

៥២
កុមារចំនួន ៥២នាក់ លែងបន្តរស់នៅតំបន់គំនរសម្រាមស្ទឹងមានជ័យ

២១
ផ្ទះត្រូវបានសាងសង់

២១
អាងស្តុកទឹកភ្លៀងត្រូវបានសាងសង់

២១
ផ្នាំងស្រូបថាមពលពន្លឺព្រះអាទិត្យត្រូវបានបំពាក់

១
អណ្តូងស្នប់

១
អណ្តូងប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ



១៤0 អ្នកស្ម័គ្រចិត្តអន្តរជាតិ
(ប្រទេសញូវហ្សេឡេន, សហរដ្ឋអាមេរិក, ប្រទេសអូស្ត្រាលី, ប្រទេសកូរ, ប្រទេសសាំងហ្គាពួរ, ប្រទេសកាណាដា, ប្រទេសអាឡឺម៉ង់, ប្រទេសម៉ាឡេស៊ី, និង ប្រទេសតណ្ឌា)

៩១ អ្នកស្ម័គ្រចិត្តក្នុងស្រុក
(ភ្នំពេញ, បាត់ដំបង, សៀមរាប, ព្រះសីហនុ, បន្ទាយមានជ័យ,ព្រៃវែង និង តាកែវ)

Habitat for Humanity Cambodia

ការសាងសង់កម្ពុជា

ជួយដល់ប្រជាជនជាង១០,០០០គ្រួសារ ស្មើនឹង ៥៥,០០០នាក់ឲ្យមានទីជំរក

ផ្តល់ការលើកទឹកចិត្ត

ប្រមូលអ្នកស្ម័គ្រចិត្ត និងគាំទ្រឲ្យបាន ១០០,០០០ នាក់

បង្កើតដើមទុន

ប្រមូលវិភាគទានឲ្យបាន ១៤ លានដុល្លារ សហរដ្ឋអាមេរិក ពីប្រភពរាជរដ្ឋាភិបាល អ្នកគាំទ្រ ម្ចាស់ជំនួយ និងខ្ជង់សន្សំពីម្ចាស់ផ្ទះ។ បង្កើតមូលនិធិបង្វិលសម្រាប់ការសាងសង់ផ្ទះ

បង្កើនសមត្ថភាព

អភិវឌ្ឍន៍បណ្តាញជាក់លាក់តាមរយៈ បុគ្គល ក្រុមហ៊ុន ក្រុមសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងរាជរដ្ឋាភិបាល ប្តេជ្ញាធ្វើការបញ្ឈប់ភាពខ្វះខាតទីជំរកសមរម្យសម្រាប់រស់នៅ

ការសាងសង់កម្ពុជា

យុទ្ធសាស្ត្រការងារតំបូងរយៈពេល ៥ ឆ្នាំ មានគោលបំណងផ្តល់នូវលំនៅដ្ឋានល្អប្រសើរជូនដល់គ្រួសារកម្ពុជា ដែលមានចំនួលទាបចំនួន ១០,០០០ គ្រួសារ និងលើកទឹកចិត្តឲ្យមានការចូលរួមពីបុគ្គល មន្ត្រី ក្រុមអង្គការ និងរាជរដ្ឋាភិបាល ដើម្បីជំរុញឲ្យមានការផ្លាស់ប្តូរទៅលើជំណោះស្រាយលំនៅដ្ឋានជូនដល់ប្រជាជនកម្ពុជា ដែលខ្វះទីកន្លែងសមរម្យហៅថាផ្ទះ។



តំបន់កំពុងមានប្រតិបត្តិការ តំបន់គំរោងប្រតិបត្តិការអនាគត

ហិរញ្ញវត្ថុ

ចំនួល

- ៤៨% មូលនិធិគ្រឹះ - $៥៧៨,៩៨៧
- ២៤% បុគ្គល - $២៩៦,៩៧១
- ៨% ពហុតោភាគី - $១០២,៦៦៧
- ៥% វិភាគទាន - $៦៣,៣៩២
- ១% ក្រុមហ៊ុន - $ ៧,៤៤៥
- ១៤% ការលក់ផ្ទះ - $១៦៩,៨៩៧





ចំនាយ

៩0% ការចំនាយផ្ទាល់
- ផ្ទះថ្មី
- ជួសជុល និងកែលម្អរ
- ទឹកស្អាត និងអនាម័យ
- ការតភ្ជាប់បណ្តាញភ្លើង

១0% ការចំនាយមិនផ្ទាល់
- រដ្ឋបាល
- ការរៃអង្គាសមូលនិធិ
- ផ្សេងៗ

សូមថ្លែងអំណរគុណ

មូលនិធិ និងម្ចាស់ជំនួយជាលក្ខណៈបុគ្គល

- មូលនិធិជំនួយ អែលតុន ចន
- មូលនិធិសប្បុរសធម៌
- មូលនិធិថែរក្សាកុមារអន្តរជាតិអូស្ត្រាលី
- លោក ប៉ូល និង អាយលីន មុន

ម្ចាស់ជំនួយ ពហុភាគី និងទ្វេភាគី

- ធនាគារពិភពលោក
- មូលនិធិអភិវឌ្ឍសង្គមជប៉ុន
- ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ

ដៃគូសហប្រតិបត្តិការអង្គការ

- សេវាកម្មហិរញ្ញវត្ថុ ដាំលរ
- ធនាគារ ANZ រ៉ូយ៉ាល់

ម្ចាស់ជំនួយរងរបស់អង្គការលំនៅដ្ឋានមនុស្សជាតិ

- អង្គការលំនៅមនុស្សជាតិអូស្ត្រាលី
- អង្គការលំនៅដ្ឋានមនុស្សជាតិចក្រភពអង់គ្លេស
- អង្គការលំនៅដ្ឋានមនុស្សជាតិញូហ្សេឡេន
- អង្គការលំនៅដ្ឋានមនុស្សជាតិអាឡឺម៉ង់
- អង្គការលំនៅដ្ឋានមនុស្សជាតិចិន
- អង្គការលំនៅដ្ឋានមនុស្សជាតិម៉ាឡេស៊ី
- សាន់ហ្គាប្រ៊ីលវ៉ាឡ៊ី អង្គការលំនៅដ្ឋានមនុស្សជាតិ
- អេសធី ប្រ៉ែន់ណី អង្គការលំនៅដ្ឋានមនុស្សជាតិ
- សកលវិទ្យាល័យ កីតស្ស៊ីក អង្គការលំនៅដ្ឋានមនុស្សជាតិ
- សកលវិទ្យាល័យ វេសមីនស្ទើ អង្គការលំនៅដ្ឋានមនុស្សជាតិ

អ្នកកសាងសហគមន៍

- ខ្មែរសូឡា, ហ្ជេត អាឡាយអេនស៍, ខេមកេនធ៍,
  ព្រះវិហារ អាក់ធីវេទ, ដេលស៍ ហ្វាហ្ស

ដៃគូក្នុងស្រុក

- អង្គការ Maryknoll
- មជ្ឈមណ្ឌលនៃក្តីសង្ឃឹមនៃមន្ទីរពេទ្យព្រះសីហនុ
- អង្គការខេមរា
- អង្គការចែករំលែកបទពិសោធន៍ដើម្បីសម្របទៅតាមការអភិវឌ្ឍន៍
- អង្គការសង្គ្រោះកុមារអូស្ត្រាលី
- អាជ្ញាធរខេត្ត និងស្រុកបាត់ដំបង
- មូលនិធិអភិវឌ្ឍតំបន់ក្រីក្រ
- សមាគមន៍ធាងត្នោត
- មណ្ឌលសុខភាពអង្គរជុំ
- មន្ទីរកសិកម្មស្រុក
- មូលនិធិព្រះពុទ្ធសាសនាដើម្បីសហគមន៍ និងការអភិវឌ្ឍន៍
- អង្គការសាម៉ារីតាន់ ភើស
- ក្រុមយុវជនគំរូកម្ពុជា
- សាលាអន្តរជាតិណរប្រ៊ីជ
- សកលវិទ្យាល័យបញ្ញាស្រ្តនៃកម្ពុជា
- នាយកដ្ឋានអភិវឌ្ឍការងារសង្គមនៃសកលវិទ្យាល័ភូមិន្ទភ្នំពេញ
- សកលវិទ្យាល័យចៀលប្រាយ
- សកលវិទ្យាល័យន័រតុន

ប្រយុទ្ធប្រឆាំងភាពក្រីក្រ

ជួយសាងសង់ផ្ទះ

ជួយចូលរួមសាងសង់

ស្ម័គ្រចិត្ត, ស្វែងរកមតិគាំទ្រ បរិច្ចាគ

ការចូលរួមនូវពេលវេលា ប្រាជ្ញាស្មារតី និងការជ្រោមជ្រែងរបស់អ្នក ធ្វើឲ្យលំនៅដ្ឋានសមរម្យនេះ មានសម្រាប់គ្រួសារនៅក្នុងប្រទេសកម្ពុជា។ សូមចូលមកកាន់គេហទំព័រ www.habitatcambodia.org ដើម្បីជួយយើងក្នុងការជួយដល់អ្នកខ្វះខាតលំនៅដ្ឋានសមរម្យ។

រូបថត: សូមថ្លែងអំណរគុណចំពោះអ្នកដែលបានផ្តល់រូបថតដូចជា ម៉ែឃើល ហ្ហេម, នីកូឡេត ប៊ីតស៍, អ៊ីក វ៉ាសនា, ប៊ីណាដេត ប៊ូឡូឆ្យូធី
រចនាទំព័រដោយក្រុមហ៊ុន ណូវ៉ា : info@novacambodia.com

Habitat for Humanity® Cambodia

អង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា
ផ្ទះលេខ ៣៥Bis, ផ្លូវ៨៧៨
សង្កាត់ផ្សារដើមគ្រៀ, ខណ្ឌចំការមន
ភ្នំពេញ, កម្ពុជា
+៨៥៥ (0)២៣ ៩៩៧ ៨៤0
www.habitatcambodia.org